# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ដកស្រង់មកអធិប្បាយនូវគាថាមួយ
## មាននៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនា ។

www.hoksavann.org

ថ្ងៃទី២៣ មេសា ២០១២



គាថាមួយបទក្នុងគម្ពីរធម្មបទពោលថា យប់យូរសំរាប់អ្នកដែលដេកមិនលក់ យោជន៍ឆ្ងាយសំរាប់អ្នកដែលមានកម្លាំងកាយខ្សោយ វដ្តសង្សារវែងឆ្ងាយសំរាប់បុគ្គលពាលទាំងឡាយ ដែលពុំដឹងច្បាស់នូវព្រះធម៌ ចេញមកពីបាលីថា ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ ទីឃោ ពាលានំ សំសារោ សទ្ធម្មំ អវិជានតំ ។

ពាក្យថា យប់យូរសំរាប់អ្នកដែលដេកពុំលក់ បានសេចក្តីថា អ្នកដេកពុំលក់បណ្តាលមកពីការគិតច្រើន បណ្តាលមកពីការមានវិបត្តិផ្លូវចិត្តបែបណាមួយ មកពីមានជម្ងឺក្នុងខ្លួន ។ អាការៈទាំងនេះហើយ បានជាធ្វើឲ្យអ្នកនោះតែងតែគិតជាប់ជានិច្ច ក៏គិតថាយប់យូរក្រភ្លឺ ។ បើមនុស្សដេកលក់ស៊ប់រហូតដល់ភ្លឺដឹងខ្លួនតែម្តង ក៏គិតថា យប់ឆាប់ទៅវិញ ។

ពាក្យថា យោជន៍ឆ្ងាយដាច់ស្រយាល សំរាប់អ្នកដែលមានកម្លាំងកាយខ្សោយ បានសេចក្តីថា អ្នកមានកម្លាំងកាយខ្សោយ បើធ្វើដំណើរថ្មើរជើង តែងតែធ្វើដំណើរយឺត ក្រដល់ទីដៅ ដើរបានបន្តិចក៏ឈប់សម្រាក ព្រោះឆាប់អស់កម្លាំង ហើយតែងតែទន្ទឹងឲ្យដល់ឆាប់ ដូច្នេះហើយបានជាអ្នកដែលធ្វើដំណើរមានកម្លាំងខ្សោយនោះគិតថា យោជន៍ឬរយៈផ្លូវវែងឆ្ងាយណាស់ ព្រោះក្រដល់ទីដៅ ។

ពាក្យថា វដ្តសង្សារវែងឆ្ងាយសំរាប់បុគ្គលពាលទាំងឡាយ ដែលពុំដឹងច្បាស់នូវព្រះធម៌បានសេចក្តីថា ការស្លាប់កើតរបស់មនុស្សសត្វទាំងឡាយក្នុងភពបី ដែលហៅថាវដ្តសង្សារ ពុំងាយឆ្លងផុតឡើយ គឺពុំងាយឆ្លងផុតពីការកើតចាស់ឈឺស្លាប់ដល់ព្រះនិព្វាន ។ បុគ្គលពាលដែលពុំដឹងអរិយសច្ចធម៌ គឺធម៌នាំទៅកាន់ទីរំលត់ទុក្ខ តែងតែប្រព្រឹត្តធ្វើអំពើបាបកម្មផ្សេងៗ ដែលជាផ្លូវនាំទៅកាន់អបាយភូមិ៤ រងទុក្ខវេទនាដ៏យូរអង្វែង មានកើតក្នុងនរកជាដើម ។

ក្នុងព្រះពុទ្ធសាសនាមាននិយាយអំពីផ្លូវពីរប្រការ គឺបកតិមគ្គោ ផ្លូវលោកប្រក្រតីធម្មតា គឺផ្លូវធ្វើដំណើរពីទីមួយទៅកាន់ទីមួយ គេប្រើផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ពីប្រទេសមួយទៅកាន់ប្រទេសមួយ ពីទ្វីបមួយទៅកាន់ទ្វីបមួយ ទោះបីមានរយៈពេលឆ្ងាយយ៉ាងណាក៏ដោយ ក៏អាចធ្វើដំណើរទៅដល់ ។ ប៉ុន្តែផ្លូវមួយទៀត គឺវដ្តទ្វារ ផ្លូវឆ្ងាយដាច់ស្រយាល គឺវដ្តសង្សារពុំងាយឆ្លងផុតឡើយ ។

ពាក្យថា បុគ្គលពាលមិនស្គាល់ព្រះធម៌ វដ្តសង្សាររមែងវែងឆ្ងាយ ។ ពាក្យព្រះធម៌ក្នុងទីនេះ បានដល់មគ្គប្រកបដោយអង្គ៨ប្រការ គឺសម្មាទិដ្ឋិ ការយល់ត្រូវក្នុងអរិយសច្ច៤ សម្មាសង្កប្បោ ការត្រិះរិះត្រូវ មានត្រិះរិះមិនបៀតបៀនអ្នកដទៃជាដើម ពីរនេះសង្គ្រោះចូលផ្នែកបញ្ញា ។ សម្មាវាចា វាចាត្រូវ សម្មាកម្មន្តោ ការងារត្រូវ សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ ទាំងបីនេះសង្គ្រោះចូលផ្នែកសីល ។ សម្មសតិ ការនឹករលឹកត្រូវ សម្មាវាយោមោ ព្យាយាមត្រូវ សម្មសមាធិ ការដំកល់ចិត្តនឹងត្រូវ ទាំងបីនេះ សង្គ្រោះចូលក្នុងផ្នែកសមាធិ ។ មគ្គប្រកបដោយអង្គ៨ប្រការនេះ សង្គ្រោះចូលក្នុងសីលសមាធិបញ្ញានេះឯង ជាផ្លូវប្រតិបត្តិ ដើម្បីរំលត់ទុក្ខ មានជាតិទុក្ខជាដើម ។

សីលមាននាទីកំចាត់កិលេសយ៉ាងគ្រោតគ្រាត ដែលប្រព្រឹត្តទៅតាមកាយនិងវាចា ។ សមាធិមានមុខងារកំចាត់កិលេសយ៉ាងកណ្តាលដែលប្រព្រឹត្តទៅក្នុងចិត្ត បានដល់នីវរណធម៌ទាំង៥គឺ កាមច្ឆន្ទៈ ចិត្តនឹកទៅរកកាម ព្យាបាទៈ ការចងគំនុំគំគួន ថីនមិទ្ធ ចិត្តរួញរា ឧទ្ធច្ចកុក្កុច្ច ចិត្តរាយមាយនិងក្តៅក្រហាយ និងវិចិកិច្ឆា ការសង្ស័យ ។ វិបស្សនាឬបញ្ញា មាននាទីនេះ កិលេសយ៉ាងល្អិត ដែលដេកត្រាំក្នុងចិត្តមានកាមានុស័យជាដើម ។ ចំពោះវិបស្សនាបើកំណត់តាមសតិបដ្ឋាន៤ គឺកំណត់កាយ វេទនា ចិត្ត និងធម្មៈ (អារម្មណ៍) ថាគ្រាន់តែកាយ វេទនា ចិត្ត និងធម្មៈ រហូតបញ្ញាកើតឡើងឃើញការពិតថា ធម្មជាតិទាំង៤នេះ ជាសភាវធម៌កើតឡើងហើយរលត់ទៅវិញ មិនមែនជាសត្វជាបុគ្គល មានសភាពសោះសូន្យទទេ ។ គោលបំណងសំខាន់របស់វិបស្សនា គឺការលះតណ្ហានិងទិដ្ឋិ ។ តណ្ហា គឺសេចក្តីប្រាថ្នា ឯទិដ្ឋិគឺការយល់ខុស ។ សម្មាទិដ្ឋិ គឺការយល់ត្រូវក្នុងអរិយសច្ច៤ ជាពិសេសឃើញច្បាស់ក្នុងខន្ធ៥ថា ប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តា ។ កាលណាបញ្ញាកើតឡើងតាមផ្លូវ វិបស្សនាឃើញការពិត តណ្ហានិងទិដ្ឋិនឹងរលត់ដោយស្វ័យប្រវត្តិ ។

ដល់ទីបំផុត ទុក្ខបានដល់ព្រះនិព្វាន ជាឈ្មោះការរលត់តណ្ហា ឯពាក្យថានិរោធ ជាឈ្មោះការរលត់ទុក្ខដោយខន្ធ៥ពុំកើតមានតទៅទៀត ។ សេចក្តីសុខរបស់ព្រះនិព្វាន គឺសុខព្រោះពុំកង្វល់នឹងអ្វីទាំងអស់ មានកង្វល់ក្នុងខន្ធ៥ ដោយការចាស់ឈឺស្លាប់ជាដើម ។ ព្រះនិព្វានជាឈ្មោះការរលត់តណ្ហានាំឲ្យរលត់ទុក្ខ ពុំមែនជាតួអ្វីមួយដូចក្នុងសង្ខតធម៌ឡើយ ។ ដូចជា ភ្លើងចង្កៀងរលត់ដោយសារអស់គ្រឿងផ្សំ ដែលជាហេតុបច្ច័យដូចអស់ប្រេងជាដើម ។៚

* *

*